# ការជ្រើសរើសគម្រោងថាមពលដែលប្រសើរជាង

## ត្រូវប្រាកដថាអ្នកមិនចំណាយអស់ច្រើនពេកសម្រាប់ថាមពលរបស់អ្នកឡើយ

ក្រុមហ៊ុនថាមពលលក់រាយមានគម្រោងផ្សេងៗគ្នាជាច្រើន ដែលគម្រោងនីមួយៗមានតម្លៃខុសៗគ្នា សម្រាប់ការផ្គត់ផ្គង់ថាមពលដល់ផ្ទះរបស់អ្នក។ អ្នកអាចសន្សំប្រាក់បានរាប់រយដុល្លារជារៀងរាល់ឆ្នាំ ដោយការផ្លាស់ប្តូរទៅគម្រោងថាមពលដែលមានតម្លៃថោកជាង។

### សំណើផ្តល់ជូនក្នុងតម្លៃដ៏ល្អបំផុត

ប្រសិនបើអ្នកមិនមានលទ្ធភាពប្រើប្រាស់អ៊ីនធឺណិតដើម្បីចូលប្រើគេហទំព័រ Victorian Energy Compare ទេ អ្នកអាចទូរសព្ទទៅក្រុមហ៊ុនថាមពលលក់រាយរបស់អ្នក ហើយស្នើសុំប្តូរទៅ 'សំណើផ្តល់ជូនក្នុងតម្លៃដ៏ល្អបំផុត' ។ 'សំណើផ្តល់ជូនក្នុងតម្លៃដ៏ល្អបំផុត' គឺជាគម្រោងថាមពលថោកបំផុតសម្រាប់គ្រួសាររបស់អ្នក ដែលក្រុមហ៊ុនថាមពលលក់រាយបច្ចុប្បន្នរបស់អ្នកផ្តល់ជូន។

ច្បាប់នានានៅក្នុងរដ្ឋវិចថូរៀចែងថា ក្រុមហ៊ុនថាមពលត្រូវតែប្រាប់អ្នកនៅលើវិក្កយបត្ររបស់អ្នក ប្រសិនបើអ្នកអាចសន្សំប្រាក់លើគម្រោងណាមួយដែលមានតម្លៃថោកជាងនេះ។ 'សំណើផ្តល់ជូនក្នុងតម្លៃដ៏ល្អបំផុត' របស់ក្រុមហ៊ុនលក់រាយរបស់អ្នក នឹងមានដាក់បង្ហាញនៅផ្នែកខាងមុខនៃវិក្កយបត្រថាមពលរបស់អ្នករៀងរាល់ 3 ខែម្តង។ ចូររកមើលប្រអប់មួយដែលនិយាយថា 'តើអ្នកអាចសន្សំប្រាក់លើគម្រោងមួយផ្សេងទៀតបានទេ' ។

### សំណើផ្តល់ជូនជាស្វ័យប្រវត្តរដ្ឋវិចថូរៀ

សំណើផ្តល់ជូនជាស្វ័យប្រវត្តរដ្ឋវិចថូរៀ គឺជាតម្លៃអគ្គិសនីដ៏សាមញ្ញ និងត្រឹមត្រូវមួយ ដែលត្រូវបានកំណត់ជារៀងរាល់ឆ្នាំដោយរដ្ឋាភិបាលរដ្ឋវិចថូរៀ មិនមែនដោយក្រុមហ៊ុនថាមពលលក់រាយទេ។ សំណើផ្តល់ជូនជាស្វ័យប្រវត្តរដ្ឋវិចថូរៀ ផ្តល់ឱ្យគ្រួសាររដ្ឋវិចថូរៀ និងម្ចាស់អាជីវកម្មខ្នាតតូចនូវតម្លៃអគ្គិសនីសមរម្យ ប្រសិនបើពួកគេមិនអាច ឬមិនចង់ស្វែងរកគម្រោងថាមពលដែលប្រសើរជាង។

### ខិត្តប័ណ្ណព័ត៌មានថាមពលរដ្ឋវិចថូរៀ

ប្រសិនបើអ្នកចង់បានព័ត៌មានបន្ថែមអំពីគម្រោងថាមពលណាមួយ មិនថាវាជាគម្រោងបច្ចុប្បន្នរបស់អ្នក ឬគម្រោងណាមួយដែលអ្នកកំពុងគិតចង់ផ្លាស់ប្តូរនោះទេ អ្នកអាចស្នើសុំឱ្យក្រុមហ៊ុនថាមពលលក់រាយទាំងនោះផ្ញើអ៊ីមែលមកអ្នកនូវខិត្តប័ណ្ណព័ត៌មានស្តីពីថាមពលនៃគម្រោងនោះ។ ខិត្តប័ណ្ណព័ត៌មាននេះនឹងផ្តល់ឱ្យអ្នកនូវព័ត៌មានងាយយល់អំពីគម្រោងថាមពលនោះ ដូចជាតម្លៃ ថាតើមានការបញ្ចុះតម្លៃលើការបង់ទាន់ពេលវេលាឬអត់ និងរយៈពេលនៃកិច្ចសន្យា។

### របៀបស្នើសុំក្រុមហ៊ុនថាមពលលក់រាយរបស់អ្នកឱ្យប្តូរទៅ 'សំណើផ្តល់ជូនក្នុងតម្លៃដ៏ល្អបំផុត' របស់ពួកគេ

#### មុនពេលអ្នកហៅទូរសព្ទ៖

ត្រូវប្រាកដថាអ្នកមាន៖

- វិក្កយបត្រថ្មីមួយនៃអគ្គិសនី ឬឧស្ម័ន

**តើត្រូវការអ្នកបកប្រែផ្ទាល់មាត់ទេ?**
វិក្កយបត្រថាមពលរបស់អ្នក នឹងមានដាក់បញ្ចូលព័ត៌មានសម្រាប់សេវាកម្មបកប្រែផ្ទាល់មាត់ឥតគិតថ្លៃ។

#### នៅពេលអ្នកហៅទូរសព្ទ៖

សូមប្រាប់ក្រុមហ៊ុនថាមពលលក់រាយរបស់អ្នក៖

**"វិក្កយបត្ររបស់ខ្ញុំនិយាយថា ខ្ញុំអាចសន្សំប្រាក់ជាមួយនឹងគម្រោងថាមពលមួយផ្សេងទៀត។ សូមអ្នកជួយដាក់ខ្ញុំនៅក្នុងសំណើផ្តល់ជូនដ៏ល្អបំផុតនេះ"**

ក្រុមហ៊ុនថាមពលលក់រាយនឹងផ្លាស់ប្តូរគម្រោងរបស់អ្នកទៅ 'សំណើផ្តល់ជូនក្នុងតម្លៃដ៏ល្អបំផុត' ខណៈពេលដែលនៅនិយាយតាមទូរសព្ទ។ បន្ទាប់មក អ្នកនឹងចាប់ផ្តើមបង់តម្លៃថោកជាងនូវថាមពលដែលផ្គត់ផ្គង់ទៅដល់ផ្ទះរបស់អ្នក។